ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ៥៧...០១៨...០១៧...ប.ក.៧-ម

ថ្ងៃអង្គារ ៨រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការផ្សព្វផ្សាយឥណទានតាមបណ្តាប្រព័ន្ធទូរស័ព្ទ

ធនាគារជាតិនៃកម្ពុជាមានកិត្តិយស សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា នាពេលថ្មីៗនេះ មានការផ្ញើសារទាក់ទងក្នុងប្រព័ន្ធទូរស័ព្ទ ឃោសនាផ្តល់ប្រាក់កម្ចីរហ័សដោយមិនចាំបាច់មានឯកសារ ឬទ្រព្យបញ្ចាំ នៅភ្នំពេញ ក៏ដូចជានៅបណ្តារាជធានី ខេត្ត-ក្រុងនានាក្នុងប្រទេសកម្ពុជា។

ទង្វើទាំងនេះ ជាអំពើខុសច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយក្រុមហ៊ុន ឬបុគ្គលទាំងនោះមិនទទួលបានការអនុញ្ញាតឲ្យផ្តល់សេវាប្រាក់កម្ចី ពីធនាគារជាតិនៃកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងមានការប្រុងប្រយ័ត្ន ដើម្បីចៀសវាងការប្រើប្រាស់សេវាកម្ចីក្រៅផ្លូវការ ដែលអាចប្រឈមនឹងការចាញ់បោក ល្បិចកលរបស់ឈ្មួញចងការប្រាក់ និងហានិភ័យផ្សេងៗជាយថាហេតុ។


ទំនាក់ទំនង៖

អគ្គនាយកដ្ឋានត្រួតពិនិត្យ

ទូរស័ព្ទ៖ (៨៥៥) ៨៥ ៦០០ ០០២